ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១៣៩
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០២
**<u>សាលដីកា</u>**
លេខៈ ២៥២
ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............. ជាចៅក្រមរបាយការណ៍
៣-លោក ............ ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............... ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-លោក .................

**<u>តំណាងមហាអយ្យការ</u>**

-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកា៨៦(ង)ស្អួន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១០ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះ ឈសក(ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅភូមិវត្តរំដួល ឃុំចំការសំរោង ស្រុក-ខេត្តបាត់ដំបង ។ ឪពុកឈ្មោះឈន គុយ (រ) ម្តាយ ឈ្មោះអ៊ិត កាត (រ) ប្រពន្ធឈ្មោះព្រំ ចាន់ថា មានកូន០១នាក់ ។

មានមេធាវីលោក ............. ។

ចុងចម្លើយឈ្មោះ ពនស (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរលក់គ្រឿងសំណង់ ទីលំនៅសព្វថ្ងៃភូមិ១៣មករា ឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។ ឪពុកឈ្មោះអ៊ុក មិន (ស) ម្តាយឈ្មោះហាក់ ចន្ទ (ស) ប្រពន្ធឈ្មោះ លី ស្រីនាង មានកូន០១នាក់ ។

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងទាមទារប្រាក់ ៥.៨០០ ដុល្លារអាមេរិក

បានឃើញបណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះពនស ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨៦(ង)ក្បួន ចុះថ្ងៃទី០១ ខែមេសាឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៣៩ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី៣១-០១-២០០១របស់ឈ្មោះឈសកជាដើមចោទ ប្តឹងសុំទារប្រាក់ចំនួន ៥៨០០ ដុល្លា ពីឈ្មោះពនស និងប្រពន្ធឈ្មោះលី ស្រីនាង ជាចុងចម្លើយ ដោយសំអាងហេតុថា នៅក្នុងខែមិនា ឆ្នាំ១៩៩៧ ឈ្មោះពនស និងប្រពន្ធបានមកខ្ចីចងការ ប្រាក់ពីខ្លួនចំនួន៥០០០$US ដោយសន្យាជាមួយខ្លួនថា ខ្ចីតែមួយខែប៉ុណ្ណោះ និងសងវិញ ហើយ ក្នុងប្រាក់ ៥.០០០ដុល្លានេះ ឈ្មោះពនស និង នាង លី ស្រីនាង គិតការប្រាក់ឱ្យខ្លួន ៥០០ដុល្លា ក្នុងមួយខែ ។ លុះដល់កំណត់ថ្ងៃត្រូវសងហើយ ឈ្មោះពនស ពុំបានសងការ ប្រាក់ឱ្យខ្លួនសោះ ទាំងប្រាក់ដើម ក៏ពុំបានសងខ្លួនដែរ ដោយបានធ្វើកិច្ចសន្យាសងខ្លួនទាំងដើម ទាំងការចំនួន ៦.០០០ដុល្លា តែបានសងខ្លួនតែ ២០០ដុល្លាប៉ុណ្ណោះនៅសល់ចំនួន៥៨០០ដុល្លា ទៀត ពុំទាន់បានសងខ្លួនសោះ រហូតដល់សព្វថ្ងៃ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៧(ទ) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០១ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ក/ទទួលពាក្យបណ្តឹងចុះថ្ងៃទី៣១ខែមករា ឆ្នាំ២០០១ របស់ឈ្មោះឈសកជាដើមចោទ ប្តឹងសុំទាមទារប្រាក់ចំនួន ៥៨០០ដុល្លាអាមេរិក គឺឈ្មោះពនស និងនាងលី ស្រីនាង ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

ខ/ទទួលយកលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០១ របស់ឈ្មោះឈសកជាដើមចោទ ឱ្យទៅឈ្មោះហម មុនី ជាមេធាវីដំណើរក្តីជំនួស ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-ឱ្យឈ្មោះពនស និងនាង លី ស្រីនាង ជាចុងចម្លើយ :

- សងប្រាក់ដើម និងការប្រាក់សរុបចំនួន ៥៨០០ដុល្លា អាមេរិក)
- ជំងឺចិត្តចំនួន៥០០ដុល្លាអាមេរិក
- សរុបទាំងអស់ចំនួន ៦៣០០ដុល្លាអាមេរិក

ឱ្យដល់ឈ្មោះឈសកជាដើមចោទ ។ ដើមចោទទាមទារលើសពីនេះ បដិសេធចោល ។

ក្នុងករណីឈ្មោះពនស និងនាង លីស្រីនាង គ្មានប្រាក់សង ត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ឈ្មោះទាំងពីរលក់ឡាយឡុងសងបំណុល ទៅឱ្យឈ្មោះឈសកជាម្ចាស់បំណុល និងក្នុងករណីឈ្មោះពនស និងនាងលីស្រីនាង រឹងរូសមិនព្រមសង គឺត្រូវដាក់គុកបង្ខំដល់រូបកាយដើម្បីទារប្រាក់តាមការប្តឹងសុំពីម្ចាស់បំណុល ។ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ ។

- តាមមាត្រា៣.៤,២២ និង ៥៦ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- តាមមាត្រា ១,១២៥,១២៧ ,១២៨ និង ១៣៣ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ៥១ក្រ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩២ ។

៣-ឱ្យឈ្មោះពនស និង នាងលើ ស្រីនាង ជាចុងចម្លើយ បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ គឺ :

- រង្វាន់ក្រឡាបញ្ជីកត់ហិបប្រាក់ =២០០៛

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង = ១៨០០

- ចំណាយក្នុងកិច្ចស៊ើបសួរ =៥.០០០៛ សរុប ៧០០០៛

ប្រាក់នេះ បានកាត់យកពីប្រាក់ចំនួន ៧.០០០៛ ដែលដើមចោទ បានបង់រួចហើយ កាលបើផុតឧទ្ធរណ៍ ឱ្យឈ្មោះពនស និងនាងលើ ស្រីនាង សងប្រាក់ ៧.០០០៛ វិញ និងបង់ពន្ធសមាមាត្រជាប្រាក់រៀល ស្មើនឹងប្រាក់ដុល្លាចំនួន ៦៣ដុល្លាអាមេរិក ប្រាក់នេះចំនួន ៨០% ត្រូវបង់ចូលថវិការដ្ឋ និង ២០% ទៀតសម្រាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៧ក្រចុះថ្ងៃទី០៨ ខែ០៨ ខែកុម្ភៈឆ្នាំ១៩៩៣

៤-សាលក្រមនេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទ និងកំបាំងមុខចុងចម្លើយ ។

ទុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩៣ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ ពនស ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៤៧(ខ) ចុះថ្ងៃទី១៩ខែមិថុនាឆ្នាំ២០០១ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១១៨(ង) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានអ្វីមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧-៦-២០០១ របស់ឈ្មោះពនស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៤៧(ខ) ចុះថ្ងៃទី១៩-៦-២០០១ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការ ប៉ុន្តែកែប្រែចំណុចទី២ និងពន្ធសមាមាត្រទៅជា:

ក/បង្គាប់ឱ្យឈ្មោះពនស និងឈ្មោះលី ស្រីនាង ជាចុងចម្លើយ សងប្រាក់ដើមចំនួន ៥.០០០ដុល្លា (ប្រាំពាន់ដុល្លាអាមេរិក) ការប្រាក់៥% ក្នុង១ឆ្នាំ ចាប់គិតពីថ្ងៃទី១០-០៣-១៩៩៧ រហូតដល់ថ្ងៃសងគ្រប់ចំនួន ពេលអនុវត្តសងការប្រាក់ ត្រូវដកការប្រាក់២០០ដុល្លាដែលបានបង់រួច និងជម្ងឺចិត្ត ៥០០$US នៅពេលដែលសាលដីកានេះ ចូលជាស្ថាពរ ។

ខ/បង្គាប់ឲ្យចុងចម្លើយបង់ពន្ធសមាមាត្រ១%លើប្រាក់ដើមការប្រាក់និងជម្ងឺចិត្ត ។

៣/សម្រេចកាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤-សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ មេធាវីតំណាងដើមចោទ និងកំបាំងមុខចុងចម្លើយ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១០ចុះថ្ងៃទី២៨ខែមករា ឆ្នាំ២០០២ របស់ឈ្មោះពេជ្រនិស្ស័យ

ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១១៨(ង) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៦(ង)ស្នួន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី២៨-០១-២០០២ របស់ឈ្មោះពនស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ១១៨(ង) ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

៣-សាលដីការនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខតំណាងដើមចោទកំបាំងមុខចុងចម្លើយ តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៥៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះ ពនស ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៤៦(ង)ស្នួន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូល នៃសេចក្ដីសម្រេច ។

បានឃើញសារណាការពារចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះពនស។

បានឃើញសារណាតបចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០២ របស់ឈ្មោះឈសភ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ៤៦ (ង)ចុះថ្ងៃទី០១ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និងគតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះពនស ជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខ នាពេលជំនុំជំរះថា : នៅថ្ងៃទី០៩-៣-១៩៩៧ ឈ្មោះឈសភក៏បានមកផ្ទះខ្លួន ហើយបានយកប្រាក់ចំនួន ៥.០០០ដុល្លាអាមេរិក មកប្រគល់ឱ្យខ្លួនជាការចុះទុនរកស៊ីជាមួយគ្នា ។ ក្រោយពីបាន ទទួលប្រាក់ពីឈ្មោះឈសភហើយ ខ្លួនបានទៅរកស៊ីនៅប្រទេសថៃ ខ្លួនបាននិយាយប្រាប់ឈ្មោះ ឈសភពីរឿងចែកប្រាក់ចំណេញ ប៉ុន្តែឈ្មោះឈសភនិយាយថា កុំទាន់ចែកគ្នាអី ចាំកន្លះខែម្ដង ឬមួយខែម្ដង ចាំចែកគ្នា ដើម្បីទុកឱ្យចំណេញច្រើន ។ ក្រោយមកខ្លួនជួបគ្រោះមហន្តរាយ បណ្ដាលឱ្យទូករបស់ខ្លួនលិចលង់ត្រូវបាត់បង់សំភារៈអស់ ។ ឈ្មោះឈសភបានបង្ខំខ្លួន និង ប្រពន្ធខ្លួនឱ្យផ្តិតមេដៃ លើកិច្ចសន្យាជាប្រាក់ចំនួន ៦.០០០ដុល្លាអាមេរិក គឺជាប្រាក់ចងការ ឈ្មោះ ឈសភបានបង្ខាំងខ្លួនអស់រយៈពេល ៣ថ្ងៃ នៅផ្ទះប្អូនរបស់គាត់ នៅសង្កាត់ផ្សារដេប៉ូច ខ្លួនផ្តិតមេដៃឱ្យគាត់ ទើបគាត់ដោះលែងខ្លួន ។ ខ្លួនក៏មិនបានប្ដឹងសុំមោឃភាព នៃកិច្ចសន្យានេះទេ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះឈសភជាដើមចោទ និងជាចុងបណ្ដឹងសាទុក្ខ នាពេលជំនុំជំរះថា ខ្លួនបដិសេធមិនទទួលស្គាល់ទេ ពាក្យពនស និយាយនេះ ប្រាស់ចាកទាំងអស់ ឈ្មោះពនស នេះ បានមកខ្ចីចងការប្រាក់ពីខ្លួនចំនួន ៥០០០ដុល្លាអាមេរិក ដោយសន្យា គិតការប្រាក់ឱ្យខ្លួនចំនួន ៥០០ដុល្លាអាមេរិក ក្នុងមួយខែ ដោយសុំខ្ចីមួយខែ

ប៉ុណ្ណោះ និងសងវិញ ដល់រយៈពេលមួយខែ ឈ្មោះពនស ពុំបានសងប្រាក់មកខ្លួនឡើយ ហើយពុំបានឱ្យការប្រាក់ ខ្លួនទាល់តែសោះ រហូតដល់ខែទី៣ ខ្លួនក៏ទៅទារ តែឈ្មោះពនស និងប្រពន្ធថា គ្មានប្រាក់សងខ្លួនឡើយ ដោយសុំធ្វើកិច្ចសន្យាទាំងដើមទាំងការប្រាក់ចំនួន៦.០០០ដុល្លាអាមេរិក និងបានកាត់កងសាឡុងចំនួន ២០០ដុល្លាអាមេរិក នៅសល់ ៥៨០០ដុល្លាអាមេរិក ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ............ ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : មានលិខិតស្នាមត្រឹមត្រូវ ពនស ពិតជាជំពាក់ប្រាក់កូនក្តីខ្លួនចំនួន៦០០០ដុល្លាអាមេរិក និងបានកាត់សាឡុងចំនួន ២០០ដុល្លាអាមេរិក នៅសល់៥៨០០ដុល្លាអាមេរិក ។ សរុប សេចក្តីមក ពនស ពិតជាបានខ្ចីប្រាក់កូនក្តីខ្លួនពិតប្រាកដមែន ។ តុលាការជាទីគោរព បើពិនិត្យមើលឯកសារ និងចម្លើយរបស់ឈ្មោះពនស ប្រកែកគឺពន្យាពេលដើម្បីឱ្យរួចខ្លួនតែប៉ុណ្ណោះ ។ ខ្លួនសូមសំណូមពរ តុលាការកំពូល តម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ពេញទាំងមូល ។

ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយគូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់

មេធាវីដើមចោទ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់លោក ពនស ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ប្រាក់ចំនួន៥០០០ដុល្លា ដែលលោកពនសថាប្រាក់នេះជាប្រាក់ដែលលោក ឈសភយកមកដាក់ទុនរកស៊ីជាមួយខ្លួន ពុំមែនជាប្រាក់ខ្ចីចងការនោះ គឺពុំត្រឹមត្រូវទេ ពីព្រោះថា :

- តាមកំណត់ហេតុផ្សះផ្សាសំរុះសំរួលចុះថ្ងៃទី០៥ ខែកុម្ភៈឆ្នាំ២០០១ នៅ ចំពោះមុខតុលាការថ្នាក់ក្រោម លោក ពនស និងអ្នកស្រី លី ស្រីនាង បានបញ្ជាក់ទទួលស្គាល់ថា ខ្លួនពិតជាបានទទួលប្រាក់ចំនួន៥០០០$ ពីលោកឈសភដើម្បីយកទៅរកស៊ីពិតមែនតែដោយពេលនេះ ខ្លួនកំពុងជួបការខ្វះខាតខ្លាំងនោះ ខ្លួនពុំទាន់មានលទ្ធភាពសងដើមចោទទេហើយដើម្បីធានាសំណងលើប្រាក់ចំនួន ៥.០០០ដុល្លាអាមេរិកនេះ ម្តាយលោកពេជ្រនិ ស្បៃយ បានយកបង្កាន់ដៃទទួលពាក្យសុំកាន់កាប់ដី បង្កាន់ដៃបង់ប្រាក់ មកប្រគល់ឱ្យលោកឈសភតម្កល់ទុកទៀតផង ។

ពុំមានភស្តុតាងណាបញ្ជាក់ថា ប្រាក់ទំនាស់៥០០០ដុល្លាអាមេរិក ដើមចោទនិងចុងចម្លើយបានដាក់ទុនរកស៊ីចូលហ៊ុនគ្នានោះទេ ។

- យល់ឃើញថា ការដែលលោកពនស លើកឡើងនៅពេលសវនាការនេះថា លិខិតប្រគល់ប្រាក់ចំនួន ៦.០០០ ដុល្លាអាមេរិក គឺធ្វើដោយដើមចោទចាប់បង្ខាំងរូបលោក និង ប្រពន្ធគំរាមឱ្យផ្តិតមេដៃថា ខ្ចីប្រាក់នោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះតាមមាត្រា១៩នៃក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ចុះថ្ងៃទី២៨-១០-១៩៨៨ បើកិច្ចសន្យានេះ

ធ្វើឡើងដោយហិង្សាចុងចម្លើយមានសិទ្ធិប្តឹងសុំមោឃៈក្នុងរយៈពេល១ឆ្នាំ ប៉ុន្តែចុងចម្លើយពុំបានប្តឹងសុំមោឃភាព លិខិត ប្រគល់ប្រាក់នេះទេ ។ ដូច្នេះចុងចម្លើយថ្លោះសិទ្ធិក្នុងការប្តឹងសុំមោឃភាព លិខិតប្រគល់ប្រាក់ នេះហើយ ហើយ ត្រូវសងប្រាក់នេះទៅដើមចោទតាមមាត្រា២២,២៩ និង ៥៦ នៃក្រឹត្យច្បាប់លេខ៣៨ក្រ ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២៩៨៨ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៤៦(ង) ស្ទួន ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១-ទទួលបណ្តឹងសាទុក្ខលេខ១៤៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់លោកពនស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៤៦(ង)ស្ទួន ចុះថ្ងៃទី០១ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលដើមចោទ បានបង់ជួសរួចហើយគឺ:

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡបញ្ជីកាន់ហិបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប ១៩.០០០រៀល ហើយ តម្រូវឱ្យចុងចម្លើយសងប្រាក់ ១៩.០០០៛ នេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រ១% លើប្រាក់ដែលត្រូវសងទៅដើមចោទ ។

៤-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៨-១១-២០០៤និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០៤ ។